00275507

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C20/5/10

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៦)**

| | |
|---|---|
| **ចំពោះមុខ:** | **ចៅក្រម ប្រាក់ គឹមសាន ប្រធាន** |
| | **ចៅក្រម Rowan DOWNING** |
| | **ចៅក្រម ន័យ ថុល** |
| | **ចៅក្រម Katinka LAHUIS** |
| | **ចៅក្រម ហួត វុទ្ធី** |
| **កាលបរិច្ឆេទ:** | **២៩ មករា ២០០៩** |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 01 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ**

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**<u>ជនត្រូវចោទ</u>**

អៀង ធីរិទ្ធ

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY
យុង ផានិត
គឹម ម៉េងឃី
Martine JACQUIN
ម៉ុច សុវណ្ណារី
Philippe CANNONE
Pierre Olivier SUR

**<u>សហមេធាវីការពារក្តី</u>**

ផាត់ ពៅស៊ាង
Diana ELLIS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) កត់សម្គាល់ឃើញមាន “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី **អៀងធីរិទ្ធ** ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨” បានដាក់នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ (“ចម្លើយតប”) ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ (“សំណើ”)។

## I. ប្រវត្តិនីតិវិធី

២. នៅក្នុងសំណើរបស់ខ្លួន, សហព្រះរាជអាជ្ញាសន្និដ្ឋានថា “នៅពេលដែលសហព្រះរាជអាជ្ញា គាំទ្រឱ្យមានសវនាការផ្ទាល់មាត់មួយលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួននេះ បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះទាក់ទងតែទៅនឹងការបន្តថិរវេលាដែលត្រូវបានបញ្ជាក់អះអាងថាត្រឹមត្រូវក្នុងពេលថ្មីៗនេះតែប៉ុណ្ណោះ ហើយដូចនេះ មិនមានការលើកឡើងនូវទឡ្ហីករណ៍ខាងអង្គហេតុ និងអង្គច្បាប់ណាថ្មីទៀត ដែលចាំបាច់ត្រូវលើកឡើងនៅក្នុងសវនាការផ្ទាល់មាត់មួយនោះទេ។”[១]

៣. នៅក្នុងសេចក្តីបង្គាប់ចេញថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានអញ្ជើញឱ្យភាគីនានា ដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ ដាក់សេចក្តីសន្និដ្ឋានតប ត្រឹមថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩។

៤. នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩, សហមេធាវីការពារក្តីបានដាក់ “ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ” ដែលក្នុងចម្លើយតបនោះ សហមេធាវីការពារក្តី សូមជំទាស់ទៅនឹងសំណើនេះ ហើយស្នើសុំអង្គបុរេជំនុំជម្រះមេត្តាសម្រេចបញ្ហានេះដោយផ្អែកលើមូលដ្ឋាននៃសវនាការផ្ទាល់មាត់វិញ។ សហមេធាវីការពារក្តីសន្និដ្ឋានថា “ការសន្មតនៃវិធានផ្ទៃក្នុង ៧៧(៣)(ខ) គឺជាសវនាការផ្ទាល់មាត់។”[២] សហមេធាវីការពារក្តីសន្និដ្ឋានបន្តទៀតថា ដីកាសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន ដែលត្រូវបានគេប្តឹងឧទ្ធរណ៍នេះ សម្រេចបន្តឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នមួយឆ្នាំទៀត ដូច្នេះហើយ ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នពិតជាបញ្ហា

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី **អៀង ធីរិទ្ធ** ប្រឆាំងនឹង “ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន” ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ C20/5/7 វាក្យខណ្ឌទី ៤។

[២] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ C20/5/9 (“ចម្លើយតបរបស់មេធាវីការពារក្តី”) វាក្យខណ្ឌទី ៦។

ដ៏សំខាន់ចំពោះជនត្រូវចោទ ហើយគួរតែត្រូវដោះស្រាយឱ្យបានសមរម្យ។”[៣] សហមេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍ថា ភាគីទាំងអស់គួរតែត្រូវបានអនុញ្ញាតឱ្យបង្ហាញ និងពន្យល់នូវអំណះអំណាងរបស់ខ្លួនឱ្យបានពេញលេញនៅក្នុងតុលាការ ហើយបំភ្លឺអំពីការបកស្រាយខុសៗគ្នាលើអង្គច្បាប់ និងអង្គហេតុ ជាច្រើនដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា។”[៤]

៥. វិធាន ៧៧ នៃវិធានផ្ទៃក្នុង (វ.២) វិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ចែងនៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធថា:

> “៣. (ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។”

៦. ដោយទទួលស្គាល់អំពីសារៈសំខាន់នៃបណ្តឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងសេរីភាពរបស់ជនត្រូវចោទ និងដោយពិចារណាថា សហមេធាវីការពារក្តី បានស្នើសុំឱ្យមានសវនាការដេញដោល, អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការរៀបចំសវនាការនេះឡើង មុនពេលសម្រេចលើបណ្តឹងឧទ្ធរណ៍។

៧. ជាគោលការណ៍ចំបង សវនាការលើរឿងក្តីនេះ ត្រូវធ្វើឡើងជាសាធារណៈ។

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះ÷

(១) **បដិសេធចោល** សំណើសុំឱ្យធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណ៍តែប៉ុណ្ណោះ។

(២) **កំណត់** បើកសវនាការនៅថ្ងៃទី**២៤ ខែកុម្ភៈ ឆ្នាំ២០០៩** វេលាម៉ោង **៩:០០ ព្រឹក**។ និង

(៣) **អញ្ជើញ** គ្រប់ភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ចូលរួមនៅក្នុងសវនាការតាមកាលបរិច្ឆេទកំណត់។

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**

[៣] ចម្លើយតបរបស់មេធាវីការពារក្តី វាក្យខណ្ឌទី ៩ និង វាក្យខណ្ឌទី ១០។

[៤] ចម្លើយតបរបស់មេធាវីការពារក្តី វាក្យខណ្ឌទី ១០។